អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងច្រវ៉ាក់ក្រដាស**

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង(ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**គោលបំណង** ៖

**(សិក្សាសង្គម)** ប្រាប់បានពីរបៀបគូរហែករូបងាយៗតាមស្នាមចុច និងផាត់រូបភាពផ្សេងៗ និងបង្ហាញសកម្មភាពផ្សេងទៀតដែលបានបង្កើតស្នាដៃ។

បង្ហាញពីរបៀបនៃការគូរ ផាត់ ហែក កាត់ ឬការផលិតឱ្យមានសោភ័ណភាព

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសពណ៌ច្រើនកាន់តែល្អ  ការស្អិត កន្ត្រៃ

**ការរៀបចំ** ៖ ត្រៀមការស្អិត ក្រដាសពណ៌ និងកន្ត្រៃឱ្យបានគ្រប់គ្រាន់

**សេចក្ដីណែនាំ** ៖

1. ប្រាប់ក្មេងៗទាំងអស់ថាថ្ងៃនេះពួកគេនឹងធ្វើច្រវ៉ាក់ក្រដាសយ៉ាងសប្បាយរីករាយមួយ។
2. បង្ហាញក្មេងពីរបៀបនៃការធ្វើឱ្យច្បាស់លាស់ និងនៅកន្លែងខាងចុងដែលភ្ជាប់ជាមួយការស្អិតឱ្យជាប់ល្អ។
3. ចែកការស្អិត ក្រដាសពណ៌ កន្ត្រៃ
4. ដើរជុំវិញថ្នាក់ ពិនិត្យមើលពួកគេប្រសិនបើពួកគេត្រូវការឱ្យអ្នកជួយ
   - ☐ របៀបធ្វើច្រវ៉ាក់ក្រដាស
   - ☐ កាត់ក្រដាសជាខ្សែរដែលមានប្រវែល៥-១០សម ដែលកាត់ចេញពីក្រដាសទំហំA4 ឬក្រដាសអ្វីក៏បានដែរ (ធ្វើបែបនេះខ្លួនឯងក៏បាន ឬឱ្យក្មេងធំធ្វើបែបហ្នឹងដោយខ្លួងឯងក៏បានដែរ)
   - ☐ រុំក្រដាសដែលបានកាត់រួចនោះ និងបិទការនៅខាងចុងឱ្យជាប់ដើម្បីធ្វើជារង្វង់

- ☐ ទាញក្រដាសមួយទៀត ព័ទ្ធចំកណ្តាលកងរង្វង់ដែលបានធ្វើរួច បន្ទាប់មកបិទការខាងចុងដូចគ្នាដែរ ដើម្បីតគ្នាជាច្រវ៉ាក់។
- ☐ ធ្វើបែបនេះរហូតទាល់តែច្រវ៉ាក់បានប្រវែងដែលអ្នកចង់បាន ឬត្រូវការ
- ☐ ដើម្បីឱ្យក្មេងៗបានសិក្សាពីបុរេគណិតដែរ ដែលអ្នកអាចឱ្យក្មេងធ្វើទៅតាមពណ៌នីមួយៗដូចជា៖ ពណ៌ក្រហម ពណ៌លឿង ពណ៌ខៀវ ពណ៌ទឹកក្រូច...។

5. ចាប់ផ្តើមឱ្យក្មេង២នាក់ដែលមានក្រដាសនៅនឹងដៃ ចាប់ផ្តើមឱ្យក្មេងទាំង២នាក់ហ្នឹងកាន់ក្រដាសដែលខ្លួនបានកាន់ជាតួចសម្រាប់ទាក់គ្នាធ្វើជាកង បន្ទាប់មក ឱ្យក្មេងទី៣ម្តង យកកងរបស់ខ្លួនមកទាក់ចូលជាមួយកងដែលបានទាក់គ្នាបាន២កងនោះ និងបន្ទាប់មកទៀត ទាក់បែបហ្នឹងរហូត ម្តងម្នាក់ៗ រហូតអស់ក្មេងក្នុងថ្នាក់ ឬក៏ក្នុងក្មេងម្នាក់អាចលេងបាន៣ ឬ៤ ឬ៥ ដងក៏បានដែរ។ កាន់តែវែងកាន់តែល្អ ដើម្បីប្រើវាសម្រាប់តុបតែងក្នុងថ្នាក់បានផងដែរ។
6. ចុងក្រោយ ប្រាប់ក្មេងៗទាំងអស់ឱ្យរៀបចំកន្លែងលេងឱ្យបានស្អាត និងមានរបៀបរបបល្អផង ធ្វើបែបហ្នឹងជាការស្រេច។